ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥៦៣...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ភារកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មឯករាជ្យ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០២ សីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះកំណត់អំពីបែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវ ក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសនវកម្មឯករាជ្យ សម្រាប់បុគ្គលជាប់កាតព្វកិច្ច ព្រមទាំងកំណត់អំពីកាតព្វកិច្ចពាក់ព័ន្ធនានា ក្នុងគោលបំណងពង្រឹងអនុលោមភាព និងការគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងស័ក្តិសិទ្ធភាព។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ សហគ្រាស សហគ្រាសសាធារណៈ សហគ្រាសទទួលខុសត្រូវជាសាធារណៈ គម្រោងវិនិយោគ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

បច្ចេកសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម÷

- បុគ្គលជាប់កាតព្វកិច្ច សំដៅដល់ សហគ្រាស សហគ្រាសសាធារណៈ សហគ្រាសទទួលខុសត្រូវជាសាធារណៈ គម្រោងវិនិយោគ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។
- សហគ្រាស សំដៅដល់ អង្គភាព ឬគ្រឹះស្ថានដែលមានគោលដៅស្វែងរកប្រាក់ចំណេញដែលរួមមានសហគ្រាសសាធារណៈ និងសហគ្រាសឯកជន រួមទាំងធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងសហគ្រាសធុនតូច និងមធ្យម ព្រមទាំងមីក្រូសហគ្រាសផងដែរ។
- សហគ្រាសសាធារណៈ: សំដៅដល់ អង្គភាពដែលស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ជាធរមាន ។
- សហគ្រាសទទួលខុសត្រូវជាសាធារណៈ សំដៅដល់ ÷

  ១. សហគ្រាសដែលមានឧបករណ៍បំណុល ឬឧបករណ៍មូលធនផ្សេងៗរបស់សហគ្រាសនោះ ត្រូវបានធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាសាធារណៈ ឬសហគ្រាសដែលកំពុងដំណើរការនៃការបញ្ចេញនូវឧបករណ៍ទាំងនេះ សម្រាប់ធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាសាធារណៈ (ទីផ្សារភាគហ៊ុនក្នុងស្រុក ឬបរទេស ឬទីផ្សារអូធីស៊ី (Over-the-Counter) ក្នុងស្រុកឬក្នុងតំបន់ ឬ

២. សហគ្រាសកាន់កាប់ទ្រព្យសកម្ម ដែលមានកិច្ចសន្យាធានាចំពោះអ្នកដទៃជាច្រើនដែលជាផ្នែកមួយនៃធុរកិច្ចសំខាន់របស់សហគ្រាសមានជាអាទិ៍÷ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ សហជីពឥណទាន ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនជួញដូរមូលបត្រ ក្រុមហ៊ុនជើងសារមូលបត្រ និងសង្គហធន (Mutual Fund) ។

- **គម្រោងវិនិយោគ** សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានទទួលវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
- **ផលរបរ** សំដៅដល់ ផលរបរដែលកើតឡើងពីសកម្មភាពប្រតិបត្តិការអាជីវកម្មក្នុងការិយបរិច្ឆេទគណនេយ្យជាក់លាក់។
- **ទ្រព្យសកម្មសរុប** សំដៅដល់ ធនធានទាំងរយៈពេលខ្លី និងរយៈពេលវែង ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។
- **សវនកម្មឯករាជ្យ** សំដៅដល់ ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសវនករប្រតិស្រុតដែលទទួលបានអាជ្ញាបណ្ណពី **គ.ជ.គ.** ។
- **កម្មករនិយោជិត** សំដៅដល់ ជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិ ដែលបាន ធ្វើការយកកម្រៃក្រោមការដឹកនាំនិងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជន។ ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីលក្ខណៈសម្បត្តិនៃកម្មករនិយោជិត គេមិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈគតិយុត្តនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីចំនួនប្រាក់ឈ្នួលតិចឬច្រើនទេ។

## ជំពូកទី ២

## លក្ខខណ្ឌនៃការអនុវត្តកាតព្វកិច្ចសវនកម្មឯករាជ្យ

**ប្រការ ៤.-**

គ្រប់សហគ្រាសសាធារណៈ សហគ្រាសទទួលខុសត្រូវជាសាធារណៈ និងគម្រោងវិនិយោគ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ។

**ប្រការ ៥.-**

សហគ្រាស ក្រៅពីសហគ្រាសសាធារណៈ សហគ្រាសទទួលខុសត្រូវជាសាធារណៈ និងគម្រោងវិនិយោគ ដូចមានចែងក្នុងប្រការ៤ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ប្រសិនបើសហគ្រាសនោះ ស្ថិតនៅក្នុងលក្ខណវិនិច្ឆ័យយ៉ាងតិច២ (ពីរ) ក្នុងចំណោមលក្ខណវិនិច្ឆ័យ៣ (បី) ដូចខាងក្រោម ÷

- លក្ខណវិនិច្ឆ័យទី១ : មានទឹកប្រាក់ផលរបរប្រចាំការិយបរិច្ឆេទគណនេយ្យចាប់ពី ៤.០០០.០០០.០០០ (បួនប៊ីលាន) រៀល ឡើងទៅ។
- លក្ខណវិនិច្ឆ័យទី២ : មានទ្រព្យសកម្មសរុបចាប់ពី ៣.០០០.០០០.០០០ (បីប៊ីលាន) រៀល ឡើងទៅ គិតត្រឹមថ្ងៃបិទការិយបរិច្ឆេទគណនេយ្យ។
- លក្ខណវិនិច្ឆ័យទី៣ : មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី ១០០ (មួយរយ) នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

សហគ្រាស ដែលមិនស្ថិតក្នុងលក្ខណវិនិច្ឆ័យយ៉ាងតិច២ (ពីរ) ក្នុងចំណោមលក្ខណវិនិច្ឆ័យ៣ (បី) ខាងលើ អាចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។

**ប្រការ ៦.-**

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ប្រសិនបើអង្គភាពមិនស្វែងរកប្រាក់ចំណេញស្ថិតក្នុងលក្ខណវិនិច្ឆ័យទាំងពីរខាងក្រោម÷

- ចំណាយសរុបប្រចាំឆ្នាំ លើសពី ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល និង
- មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី ២០ (ម្ភៃ) នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

អង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងឡាយណាដែលមិនស្ថិតក្នុងលក្ខណវិនិច្ឆ័យទាំងពីរខាងលើ អាចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។

## ជំពូកទី ៣
## កាតព្វកិច្ចរបស់បុគ្គលជាប់កាតព្វកិច្ច

**ប្រការ ៧.-**

សហគ្រាសដែលមានកាតព្វកិច្ចអនុវត្តដូចមានចែងក្នុងប្រការ៥ ដែលធ្លាប់បានរងសវនកម្មឯករាជ្យរួចហើយ ត្រូវបន្តដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ យ៉ាងតិច ៣ (បី) ឆ្នាំជាប់ៗគ្នាបន្តទៀត ទោះបីជាក្នុងករណីដែលសហគ្រាសនោះមិនស្ថិតក្នុងលក្ខណវិនិច្ឆ័យក៏ដោយ។

**ប្រការ ៨.-**

ប្រសិនបើបុគ្គលជាប់កាតព្វកិច្ច មិនមានសកម្មភាពពាណិជ្ជកម្ម ឬសកម្មភាពប្រតិបត្តិការ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្តបន្ទាប់គ្នា គិតចាប់ពីថ្ងៃបិទបញ្ជប់ការិយបរិច្ឆេទគណនេយ្យចុងក្រោយ បុគ្គលជាប់កាតព្វកិច្ចនោះអាចដាក់ពាក្យស្នើសុំមក **ក.ជ.គ.** ក្នុងការមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

**ប្រការ ៩.-**

ការងារធ្វើសវនកម្មឯករាជ្យ និងការបោះផ្សាយមតិសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបញ្ចប់ឱ្យបានរួចរាល់មិនឱ្យហួសពីរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ ក្នុងករណីមិនអាចអនុវត្តតាមពេលកំណត់នេះ បុគ្គលជាប់កាតព្វកិច្ចអាចស្នើសុំពន្យារពេលមក **ក.ជ.គ.** ដោយមានបញ្ជាក់ពីមូលហេតុសមស្រប។

**ប្រការ ១០.-**

បុគ្គលជាប់កាតព្វកិច្ចត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច និងរបាយកាណ៍សវនកម្មឯករាជ្យ មកអគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.** មិនឱ្យហួសពីរយៈពេល ៦ (ប្រាំមួយ) ខែ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

**ប្រការ ១១.-**

ការធ្វើសវនកម្មឯករាជ្យ លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ ២០២០ ត្រូវបានកំណត់ថាជាការធ្វើសវនកម្មឯករាជ្យ ឆ្នាំទី ១។ សវនករមិនត្រូវផ្តល់សេវាសវនកម្មជូនសហគ្រាស ឬ អង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពីប្រាំឆ្នាំបន្តបន្ទាប់គ្នាឡើយ។

**ប្រការ ១២.-**

បុគ្គលជាប់កាតព្វកិច្ច ត្រូវបង់កម្រៃសេវារក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៣.-**

នីតិវិធីនិងបែបបទសម្រាប់ការបញ្ជូននិងរក្សាទុករបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់បុគ្គលជាប់កាតព្វកិច្ច ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.**។

## ជំពូកទី ៤

## សិទ្ធិ និង កាតព្វកិច្ចរបស់មន្ត្រី

**ប្រការ ១៤.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.** មានកាតព្វកិច្ចរក្សាទុករបាយការណ៍ទាំងនោះ និងមានសិទ្ធិនៅក្នុងការប្រើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ ដើម្បីអនុវត្តមុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើអនុលោមភាពនៃរបាយការណ៍ទៅនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាពាក់ព័ន្ធជាធរមាន។

**ប្រការ ១៥.-**

ថ្នាក់ដឹកនាំនិងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.** ត្រូវរក្សាការសម្ងាត់ទាំងព័ត៌មានហិរញ្ញវត្ថុនិងព័ត៌មានមិនមែនហិរញ្ញវត្ថុរបស់បុគ្គលជាប់កាតព្វកិច្ច។

ថ្នាក់ដឹកនាំនិងមន្ត្រីណាធ្វើឱ្យបែកធ្លាយព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុរបស់បុគ្គលជាប់កាតព្វកិច្ច ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ១៦.-**

**គ.ជ.គ.** រក្សាសិទ្ធិក្នុងការផ្តល់របាយការណ៍ហិរញ្ញវត្ថុដល់ស្ថាប័នសាធារណៈមានសមត្ថកិច្ច ក្នុងករណីមានការស្នើសុំ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**ប្រការ ១៧.-**

ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានក្នុងវិស័យគណនេយ្យនិងសវនកម្មជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលជាប់កាតព្វកិច្ចដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវទទួលរងការពិន័យអន្តរការណ៍ពី ក.ជ.គ. ដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក. ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ១៨.-**

ប្រកាសលេខ ៦៤៣ សហវ.ប្រក. ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.-**

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ អគ្គលេខាធិការនៃ ក.ជ.គ. ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ